២០១៧

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ៧៥៤ MIH / ២០១៧

# សេចក្ដីសម្រេច
# ស្ដីពី
# ការបង្កើតគណៈកម្មការបច្ចេកទេសមន្ទីរពិសោធន៍វេជ្ជសាស្ត្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម
## និងជាប្រធានក្រុមប្រឹក្សាជាតិវាយតម្លៃទទួលស្គាល់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៣ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីស្តង់ដារកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញប្រកាសលេខ ៤៣៥ MIH / 2014 ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០១៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានវាយតម្លៃទទួលស្គាល់
- បានឃើញប្រកាសលេខ ៥២៣ MIH / 2014 ចុះថ្ងៃទី ០៣ ខែកញ្ញា ឆ្នាំ២០១៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិវាយតម្លៃទទួលស្គាល់
- បានឃើញប្រកាសលេខ ១៦១ MIH / 2015 ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០១៥ ស្ដីពីការកែសម្រួលមុខងារ និងភារកិច្ចរបស់នាយកដ្ឋានវាយតម្លៃទទួលស្គាល់
- យោងតាមស្មារតីអង្គប្រជុំក្រុមប្រឹក្សាជាតិវាយតម្លៃទទួលស្គាល់លើកទី២ ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧

## សម្រេច

**ប្រការ១._**

ត្រូវបានបង្កើតគណៈកម្មការបច្ចេកទេសមន្ទីរពិសោធន៍វេជ្ជសាស្ត្រ Technical Committee (TC) for Medical Testing អនុលោមតាមស្តង់ដារអន្តរជាតិ ISO 15189 ដែលមានសមាសភាពដូចខាងក្រោម៖



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ២១១ ៨៩៤
អ៊ីមែល: mih.smcabinet@gmail.com

| | | |
|---|---|---|
| ១- លោកវេជ្ជបណ្ឌិត **សៅ សុគន្ធណា** | អនុប្រធាននាយកដ្ឋានមន្ទីរពេទ្យ តំណាងក្រសួងសុខាភិបាល | ប្រធាន |
| ២- លោកសាស្ត្រាជំនួយ **ច្រឹង សុភាព** | ប្រធានមន្ទីរពិសោធន៍ មន្ទីរពេទ្យព្រះកុសមៈ តំណាងក្រសួងសុខាភិបាល | អនុប្រធាន |
| ៣- លោកស្រី **ប៊ូ ម៉េងចេង** | ប្រធានការិយាល័យ តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៤- លោកស្រីឱសថការីឯកទេសផ្នែកវេជ្ជជីវសាស្ត្រ **ស្រី វិសូរ** | ប្រធានមន្ទីរពិសោធន៍ មន្ទីរពេទ្យកុមារជាតិ តំណាងក្រសួងសុខាភិបាល | សមាជិក |
| ៥- លោកវេជ្ជបណ្ឌិត **គឹម ហួត** | ប្រធានផ្នែកលោហិតសាស្ត្រ វិទ្យាស្ថានជាតិសុខភាពសាធារណៈ តំណាងក្រសួងសុខាភិបាល | សមាជិក |
| ៦- លោក **ចាប វណ្ណៈ** | អនុប្រធានមន្ទីរពិសោធន៍នៃមជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា នៃវិទ្យាស្ថានស្តង់ដារកម្ពុជា តំណាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ៧- លោកស្រីឱសថការី **អ៊ុច មោនីភាព** | អនុប្រធានការិយាល័យសេវាមន្ទីរពិសោធន៍ នៃនាយកដ្ឋានមន្ទីរពេទ្យ តំណាងក្រសួងសុខាភិបាល | សមាជិក |

**ប្រការ២._**

គណៈកម្មការបច្ចេកទេសមន្ទីរពិសោធន៍វេជ្ជសាស្ត្រ មានភារកិច្ចដូចតទៅ៖

- រៀបចំបង្កើតលក្ខខណ្ឌបច្ចេកទេសជាក់លាក់តាមនីតិវិធី និងពិធីការ (Protocol) នៃមន្ទីរពិសោធន៍វេជ្ជសាស្ត្រ ស្តីពីគុណភាព សមត្ថភាព និងសុវត្ថិភាព ដើម្បីជួយគាំទ្រដល់កិច្ចដំណើរការប្រព័ន្ធវាយតម្លៃទទួលស្គាល់ជាតិកម្ពុជា
- ផ្តល់យោបល់លើគោលការណ៍ ការងារវាយតម្លៃទទួលស្គាល់ នៃមន្ទីរពិសោធន៍វេជ្ជសាស្ត្រ
- សហការ និងគាំទ្រដល់ផ្នែកជំនាញនៃនាយកដ្ឋានវាយតម្លៃទទួលស្គាល់ លើការងារវាយតម្លៃទទួលស្គាល់ដល់មន្ទីរពិសោធន៍វេជ្ជសាស្ត្រ។

**ប្រការ៣._**

គណៈកម្មការបច្ចេកទេសមន្ទីរពិសោធន៍វេជ្ជសាស្ត្រ ត្រូវចូលរួមប្រជុំឲ្យបាន ទៀងទាត់តាមការអញ្ជើញរបស់ប្រធាននាយកដ្ឋានវាយតម្លៃទទួលស្គាល់ ដែលជាសមាជិកអចិន្ត្រៃរបស់ក្រុមប្រឹក្សាជាតិវាយតម្លៃទទួលស្គាល់។ កិច្ចប្រជុំអាចប្រព្រឹត្តទៅបានលុះត្រាតែមានកូរ៉ុមលើសពីពាក់កណ្តាលនៃសមាជិកសរុប។ រាល់សេចក្តីសម្រេចណាមួយ នៃអង្គប្រជុំ របស់គណៈកម្មការបច្ចេកទេសត្រូវយកតាមមតិភាគច្រើនដាច់ខាតនៃសមាជិកវត្តមានក្នុងកិច្ចប្រជុំ។ នៅពេលប្រធានអវត្តមាន កិច្ចប្រជុំអាចដំណើរការទៅបានក្រោមការដឹកនាំរបស់អនុប្រធាន។ ក្នុងករណីអវត្តមានប្រធាន និងអនុប្រធាន ការប្រជុំត្រូវដឹកនាំដោយសមាជិកតំណាង ណាម្នាក់ដែលបានទទួលការប្រគល់សិទ្ធិ ពីសមាជិកមានវត្តមានក្នុងពេលប្រជុំ។



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី ៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣២១១ ៧៧៥
អ៊ីម៉ែល: mih.smcabinet@gmail.com

**ប្រការ៤._**

គណៈកម្មការបច្ចេកទេសមន្ទីរពិសោធន៍វេជ្ជសាស្រ្តមាននាយកដ្ឋានវាយតម្លៃទទួលស្គាល់ជាលេខាធិការដ្ឋានធ្វើការសម្របសម្រួលរាល់ការងារទាំងអស់នៃគណៈកម្មការបច្ចេកទេសមន្ទីរពិសោធន៍វេជ្ជសាស្ត្រ។

**ប្រការ៥._**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៦._**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានវិទ្យាស្ថាន ប្រធានមជ្ឈមណ្ឌល ប្រធាននាយកដ្ឋានវាយតម្លៃទទួលស្គាល់ គ្រប់អង្គភាពពាក់ព័ន្ធ និងសមាសភាពគណៈកម្មការដូចមានចែងក្នុងប្រការ១ មានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែ តុលា ឆ្នាំ២០១៧

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**និងជាប្រធានក្រុមប្រឹក្សាជាតិវាយតម្លៃទទួលស្គាល់**

**ចម ប្រសិទ្ធ**

**កន្លែងទទួល ៖**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ក្រុមប្រឹក្សាជាតិវាយតម្លៃទទួលស្គាល់
  *«ដើម្បីជូនជ្រាប»*
- ដូចប្រការ៦ «ដើម្បីអនុវត្ត»
- ឯកសារ-កាលប្បវត្តិ



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី ៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)
ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: mih.smcabinet@gmail.com